ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ ៧៩៤/ រប.អដក
/១៩

## សេចក្ដីជូនដំណឹង
## ស្ដីពី
## ការរៀបចំពិធីទទួលទានអាហារពេលល្ងាច និងសម្ដែងសិល្បៈក្នុងតំបន់រមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍ ម្ចាស់សណ្ឋាគារ និងក្រុមហ៊ុនឯកជនទាំងអស់ ដែលស្នើសុំរៀបចំពិធីទទួលទានអាហារពេលល្ងាច និងសម្ដែងសិល្បៈក្នុងតំបន់រមណីយដ្ឋានអង្គរ មេត្តាជ្រាបថា ដើម្បីលើកគុណតម្លៃបេតិកភណ្ឌវប្បធម៌នៃតំបន់រមណីយដ្ឋានអង្គរឱ្យមានកិត្យានុភាពខ្ពង់ខ្ពស់ ក៏ដូចជាលើកកម្ពស់ការផ្ដល់សេវាកម្ម ផលិតផលទេសចរណ៍ឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការទាក់ទាញភ្ញៀវទេសចរអន្តរជាតិ មកកាន់ទឹកដីអង្គរខេត្តសៀមរាប អាជ្ញាធរជាតិអប្សរាសូមធ្វើការណែនាំដូចខាងក្រោម៖

១- អ្នករៀបចំកម្មវិធីត្រូវផ្ដល់ព័ត៌មានជូនភ្ញៀវទេសចរជាមុន អំពីការចូលរួមអនុវត្តក្រមប្រតិបត្តិអង្គរ។

២- ការប្រើប្រាស់គេសជ្ជៈដែលមានជាតិអាកុលត្រូវកម្រិតមិនឱ្យលើស ១៧ដឺក្រេ នៅតាមទីតាំងមួយចំនួនដែលកំណត់ដោយអាជ្ញាធរជាតិអប្សរា ។

៣- ភ្ញៀវដែលចូលរួមកម្មវិធី មិនអនុញ្ញាតឱ្យចូលទៅក្នុងប្រាសាទជាដាច់ខាត។ ក្នុងករណីមានការបំពាន អ្នករៀបចំកម្មវិធីត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់។

៤- ក្រុមសិល្បៈនានាដែលសម្ដែងក្នុងតំបន់រមណីយដ្ឋានអង្គរត្រូវមានវិញ្ញាបនបត្រទទួលស្គាល់ដោយមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត។

អាស្រ័យហេតុនេះ សូមគ្រប់ក្រសួង មន្ទីរ ស្ថាប័នជាតិ-អន្តរជាតិ សមាគមទីភ្នាក់ងារទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍ ម្ចាស់សណ្ឋាគារ និងក្រុមហ៊ុនឯកជនទាំងអស់មេត្តាចូលរួមអនុវត្ត ដើម្បីលើកតម្លៃបេតិកភណ្ឌវប្បធម៌នៃតំបន់រមណីយដ្ឋានអង្គរឱ្យមានកិត្យានុភាពខ្ពង់ខ្ពស់។

ថ្ងៃចន្ទ ១០កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
សៀមរាប ថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០១៩

អគ្គនាយក

ហង់_ពៅ

**ចម្លងជូន៖**
- គ្រប់ក្រសួង-ស្ថាប័ន
- សាលាខេត្តសៀមរាប
- អង្គភាពនគរបាលការពារបេតិកភណ្ឌ ប្រចាំខេត្តសៀមរាប
- អង្គភាពនគរបាលទេសចរណ៍ ប្រចាំខេត្តសៀមរាប
- គ្រឹះស្ថានអង្គរ
  "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ


ភ្នំពេញ:
អគារលេខ៨៤ ផ្លូវលេខ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ
ទូរស័ព្ទ/ទូរសារ៖ ០២៣ ២១៥ ៩៣១/ ០២៣ ២១៥ ៩៣៦

អាជ្ញាធរដើម្បីការពារតំបន់រមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: apsaraauthority.gov.kh

សៀមរាប:
ភូមិបន្ទាយ ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ៖ ០៦៣ ៩៦៥ ៥៩៧/ ០៦៣ ៩៦៥ ៥៩៦